01674174

F68

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះតុលាការកំពូល

Supreme Court Chamber

Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jul-21, 08:43
CMS/CFO: Sann Rada

នៅចំពោះមុខ៖

**ចៅក្រម គង់ ស្រីម ប្រធាន**

**ចៅក្រម Chandra Nihal JAYASINGHE**

**ចៅក្រម សោម សិរីវឌ្ឍ**

**ចៅក្រម Florence Ndepele Mwachande MUMBA**

**ចៅក្រម ម៉ុង មុន្នីចរិយា**

**ចៅក្រម Maureen Harding CLARK**

**ចៅក្រម យ៉ា ណារិន**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០២១

ភាសាដើម៖ ខ្មែរ/អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

---

# សេចក្តីជូនដំណឹងអំពីការធ្វើតេស្តសាកល្បងត្រៀមសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២

---

**សហព្រះរាជអាជ្ញា**

ជា លាង

Brenda HOLLIS

**ជនជាប់ចោទ**

ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Megan HIRST

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ (“អង្គជំនុំជម្រះតុលាការកំពូល”)

**បានទទួល**បណ្តឹងសាទុក្ខរបស់ ខៀវ សំផន និងសហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ និងបានជូនដំណឹងនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩[1]

**អនុលោមតាម** កថាខណ្ឌ ៦០ នៃ*សេចក្តីសម្រេចស្តីពីការពន្យារពេលសវនាការ* ដែលក្នុងនោះអង្គជំនុំជម្រះបានបញ្ជាក់ថា “[...] ការិយាល័យរដ្ឋបាលត្រូវរៀបចំផ្តល់ការហ្វឹកហាត់ដល់ភាគី និងអង្គជំនុំជម្រះលើកម្មវិធីកុំព្យូទ័រប្រើប្រាស់ប្រព័ន្ធសោតទស្សន៍ ហើយបន្ទាប់មកត្រូវធ្វើតេស្តសាកល្បងជាមួយអ្នកចូលរួមសវនាការទាំងអស់ឱ្យបានយ៉ាងតិច ២១ ថ្ងៃមុនពេលចាប់ផ្តើមសវនាការ។ អង្គជំនុំជម្រះពិចារណាឃើញថា វិធានការទាំងនេះជាការចាំបាច់ក្នុងការធានាថា សវនាការអាចដំណើរការទៅប្រកបដោយអត្ថន័យក្នុងកម្រិតល្អប្រសើរតាមដែលអាចធ្វើទៅបាន”[2]

**កត់សម្គាល់**ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ដែលអង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទសវនាការលើបណ្តឹងសាទុក្ខនេះនៅថ្ងៃទី ១៦ ដល់ ២៧ ខែ សីហា ឆ្នាំ ២០២១[3]

**កត់សម្គាល់ឃើញថា** ការិយាល័យរដ្ឋបាលនឹងជួយសម្រួលការធ្វើតេស្តសាកល្បងនេះ និងសម្របសម្រួលជាមួយភាគី និងអ្នកចូលរួមលើទម្រង់បែបបទសវនាការឱ្យបានមុនថ្ងៃធ្វើតេស្ត

---

[1] ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ប្រតិចារិកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E1/529.1។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងនៃសំណុំរឿង ០០២/០២ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E465។

[2] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំពន្យារពេលសវនាការបណ្តឹងសាទុក្ខ និងសេចក្តីណែនាំពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទថ្មី និងទម្រង់បែបបទសម្រាប់សវនាការបណ្តឹងសាទុក្ខ (“សេចក្តីសម្រេចស្តីពីការពន្យារពេល”) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០២១ ឯកសារលេខ F65។

[3] ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០២១ ឯកសារលេខ F66។

**អាស្រ័យហេតុនេះ៖**

**ជូនដំណឹង**ដល់ភាគី និងអ្នកចូលរួម ព្រមទាំងផ្នែកគ្រប់គ្រងតុលាការ ផ្នែកបកប្រែ ផ្នែកព័ត៌មានវិទ្យា និងទំនាក់ទំនង បុគ្គលិកសន្តិសុខ ថា តេស្តសាកល្បងនេះត្រូវធ្វើឡើងនៅក្នុងបរិវេណនៃ អ.វ.ត.ក. នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០២១ វេលាម៉ោង ៩ និង ៣០ ព្រឹក សម្រាប់ត្រៀមសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២។

**រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០២១**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**